**សលាកប័ត្រព័ត៌មាន** ៖ ការចាប់ខ្លួនលោក វង្ស សុខខេងលី បង្ហាញពីការបន្តគំរាមកំហែងរបស់នគរបាល

**កាលប្បវត្តិ** ៖ ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន

**ទិដ្ឋភាពរួម** ៖ លោក វង្ស សុខខេងលី ត្រូវបានឃុំខ្លួនដោយពុំមានការចោទប្រកាន់កាលពីថ្ងៃច័ន្ទ ទី០៤ ខែមករា ឆ្នាំ២០១៦ ដើម្បីសាកសួរនិង " អប់រំ " ពាក់ព័ន្ធក្នុងសកម្មភាពតវ៉ាដោយសន្តិវិធីរបស់លោក។ នគរបាលក៏ប៉ុនប៉ងឱ្យលោកចុះហត្ថលេខាលើលិខិតសន្យាបញ្ឈប់ចូលរួមក្នុងការតវ៉ា។ ការបំពានអំណាចដោយខុសច្បាប់ពីសំណាក់អាជ្ញាធរ ជាការរំលោភទៅលើសិទ្ធិមនុស្សនិងជាផ្នែកមួយនៃយុទ្ធសាស្ត្រគំរាមកំហែងដែលកំពុងតែកើតមាននៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## សេចក្តីផ្តើម

នៅថ្ងៃច័ន្ទ ទី០៤ ខែមករា ឆ្នាំ២០១៦ លោក វង្ស សុខខេងលី ត្រូវបានឃុំខ្លួនអស់រយៈពេលប្រមាណប្រាំមួយម៉ោងនៅខេត្តព្រះវិហារ។ លោកត្រូវបានឃុំខ្លួនដោយពុំមានការចោទប្រកាន់ដើម្បីសាកសួរអំពីការចូលរួមរបស់លោកក្នុងការតវ៉ាទំនាស់ដីធ្លីមួយតាមការលើកឡើងរបស់អភិបាលរងខេត្តព្រះវិហារ លោក ស៊ូ សេរី ការឃុំខ្លួននោះគឺដើម្បី "អប់រំគាត់" ដោយសារបានចូលរួមក្នុងការតវ៉ានេះ។[1] មានការរាយការណ៍ផងដែរថា នគរបាលមិនព្រមប្រាប់ពីបទចោទប្រកាន់ដែលលោក សុខខេងលី កំពុងជាប់ឃុំនោះទេ។ សកម្មជននិងតំណាងសហគមន៍បានចូលរួមក្នុងការតវ៉ាដោយសន្តិវិធីទាក់ទិនទៅនឹងទំនាស់ដីធ្លីចំនួនពីរករណីនៅក្នុងស្រុកត្បែងមានជ័យនិងស្រុករវៀង ជាទីកន្លែងដែលអ្នកភូមិបានត្អូញត្អែរថាសម្បទានដីសេដ្ឋកិច្ចបានរំលោភទៅលើដីធ្លីរបស់ពួកគាត់។ លោកត្រូវបានដោះលែងវិញ បន្ទាប់ពីអ្នកតវ៉ាបានបិទច្រកផ្លូវចូលទៅកាន់សាលាខេត្ត។ នៅមុនពេលដោះលែងលោក សុខខេងលី នគរបាលបានព្យាយាមបង្ខំឱ្យលោកចុះហត្ថលេខាលើលិខិតស្នាមដែលចែងថាលោកនឹងប្រាប់អ្នកតវ៉ាផ្សេងទៀតនៅខាងក្រៅបរិវេណសាលាខេត្តឱ្យចាកចេញ។

ការចាប់ខ្លួនតាមអំពើចិត្តទៅលើអ្នកតវ៉ានេះដែលតែងតែធ្វើឡើងដើម្បីបំបែកការតវ៉ា ឬដើម្បីហេតុផលនយោបាយផ្សេងទៀតបានក្លាយជារឿងសាមញ្ញទៅហើយនៅកម្ពុជា។ រីឯរឿងសាមញ្ញផ្សេងទៀតនោះគឺការប្រើយុទ្ធសាស្ត្របង្ខិតបង្ខំអ្នកជាប់ឃុំឱ្យចុះហត្ថលេខាលើលិខិតស្នាមនានានៅមុនពេលដោះលែងអ្នកទាំងនោះដោយគំរាមថានឹងចាត់វិធានការ ឬដកហូតសិទ្ធិមួយចំនួន។ ការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ទាំងពីរនេះរំលោភទៅលើសិទ្ធិសេរី

[1] ឡាយ សាមាន "អាជ្ញាធរដោះលែងតំណាងអ្នកតវ៉ាក្រោយឃាត់ខ្លួនជាង ៥ ម៉ោង" កាសែត*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ អាចស្វែងរកបានតាមរយៈ៖ http://bit.ly/1mxHxe9។

ភាពខាងការដើរហើរ ការប្រមូលផ្តុំនិងការបញ្ចេញមតិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា("រដ្ឋធម្មនុញ្ញ")។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះអាជ្ញាធរកម្ពុជាបានកំពុងបង្កើនការប្រើប្រាស់យុទ្ធសាស្ត្រគំរាមកំហែងដើម្បីបញ្ឈប់ការតវ៉ាដោយសន្តិវិធីនានានិងបង្ក្រាបនូវភាពសកម្មនិយម។

សាលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក") ដែលជាអង្គមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

## បរិបទនៃការចាប់ខ្លួន ៖ ទំនាស់ដីធ្លីដ៏រាលដាលនៅកម្ពុជា

លោក សុខខេងលី គឺជាតំណាងសហគមន៍ម្នាក់នៅក្នុងឃុំរូសរាន់ ស្រុករវៀង ខេត្តព្រះវិហារ។ អ្នកភូមិបានរស់នៅទីនោះចាប់តាំងពីឆ្នាំ១៩៩៧/១៩៩៨ ។ នៅឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានផ្តល់សម្បទានដីសេដ្ឋកិច្ចទំហំ ៩,០០០ ហិកតាទៅឱ្យក្រុមហ៊ុនចិនឈ្មោះឡាន ហ្វេង[2]ដែលបានរំលោភទៅលើដីធ្លីរបស់អ្នកភូមិ។ ជាការឆ្លើយតប សហគមន៍បានដាក់សំណើទៅកាន់សាលាខេត្តព្រះវិហារដើម្បីអន្តរាគមន៍ ប៉ុន្តែមិនទទួលបានដំណោះស្រាយនោះឡើយ។ ហេតុនេះហើយលោក សុខខេងលី និងអ្នកភូមិផ្សេងទៀតបានតវ៉ាដើម្បីព្យាយាមដោះស្រាយទំនាស់របស់ពួកគាត់ដោយខ្លួនឯងជាមួយក្រុមហ៊ុន។ នាពេលថ្មីៗនេះ អ្នកភូមិបានប្រមូលផ្តុំគ្នាសម្រាន្តនៅពីមុខសាលាខេត្តដើម្បីរង់ចាំការឆ្លើយតបពីអភិបាលខេត្ត។

នៅក្នុងខែតុលា ឆ្នាំ២០១៥ លោក សុខខេងលី និងតំណាងអ្នកភូមិបួននាក់ផ្សេងទៀតត្រូវបានសាលាដំបូងខេត្តព្រះវិហារកោះហៅពាក់ព័ន្ធនឹងសកម្មភាពតវ៉ារបស់ពួកគាត់ ក្រោមការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ)។ ដោយសារតែពួកគាត់គ្មានមេធាវីការពារផ្នែកច្បាប់ ដូច្នេះហើយពួកគាត់បានស្នើសុំពន្យារពេលសវនាការ។ តំណាងអ្នកភូមិទាំងនេះនឹងត្រូវចូលបង្ហាញខ្លួននៅសាលាដំបូងខេត្តជាថ្មីនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦។

## ព្រឹត្តិការណ៍វិវត្តក្នុងឆ្នាំ២០១៥ ៖ ការឃុំខ្លួនតាមអំពើចិត្ត និងការដោះលែងមានលក្ខខណ្ឌ

ការឃុំខ្លួនទៅលើអ្នកតវ៉ាមានការវិវត្តជាបន្តបន្ទាប់ក្នុងឆ្នាំ២០១៥ និងហាក់ដូចជាបម្រុងនឹងបន្តកើតឡើងនៅឆ្នាំនេះទៀត៖

- **ខែកុម្ភៈ** ៖ តំណាងសហជីពត្រូវបានឃុំខ្លួនបន្ទាប់ពីបានធ្វើការចែកចាយលិខិតទៅឱ្យកម្មកររោងចក្រដែលអះអាងជុំវិញអំពើពុករលួយក្នុងសហជីពរបស់ពួកគេ។ តំណាងសហជីពទាំងនោះត្រូវបានដោះលែងវិញ

[2] អូន ភាព "គ្រួសារជនជាតិគួយជាច្រើនគ្រួសារតវ៉ាជំទាស់នឹងក្រុមហ៊ុនស្កអំពៅ" កាសែត *ដឹ ខេមបូឌាដេលី* ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈ ៖http://bit.ly/1kRJTTr។

នៅរយៈពេលពីរម៉ោងបន្ទាប់ ក្រោយមកពួកគេត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើលិខិតស្នាមដោយសន្យាបញ្ឈប់ចែកចាយលិខិតដោយគ្មានការអនុញ្ញាតពីអាជ្ញាធរ។[3]

- **ខែមិថុនា ៖** អ្នកតវ៉ាចំនួនបីនាក់មកពីអង្គការមាតាធម្មជាតិត្រូវបានចាប់ខ្លួនខណៈពេលព្យាយាមធ្វើការតវ៉ាដោយសន្តិវិធីប្រឆាំងទៅនឹងការបូមខ្សាច់នៅខេត្តកោះកុង ស្ថិតនៅខាងក្រោមទីរដ្ឋសភាក្នុងរាជធានីភ្នំពេញ។ នគរបាលក៏បានចាប់ខ្លួនអ្នកឃ្លាំមើលការតវ៉ាម្នាក់ផងដែរដែលនៅជាមួយអ្នកតវ៉ាទាំងបីនាក់នាពេលនោះ។ បុរសទាំងបួននាក់នោះត្រូវបានដោះលែងវិញដោយពុំមានការចោទប្រកាន់ ប៉ុន្តែនៅមុនពេលដោះលែង សកម្មជនទាំងបីនាក់នោះត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើលិខិតស្នាមដែលសន្យាថានឹងធ្វើការជូនដំណឹងដល់អាជ្ញាធរជាមុននៅពេលធ្វើការតវ៉ានាពេលក្រោយៗ។[4]
- **ខែកញ្ញា ៖** លោក សុត ពិសិដ្ឋ ត្រូវបានឃុំខ្លួននិងបានតម្រូវឱ្យចុះហត្ថលេខាលើលិខិតស្នាមមួយច្បាប់ ហើយក្រោយមកត្រូវបានដោះលែងវិញ។ លោកបានរៀបចំការបិទផ្លូវតវ៉ាជំទាស់ទៅនឹងវត្តមានក្រុមហ៊ុនចិនមួយនៅលើដីធ្លីរបស់អ្នកភូមិ។ លិខិតនោះបានតម្រូវឱ្យលោកបញ្ឈប់ការបិទផ្លូវ ឬដឹកនាំការតវ៉ាទៀត តែយ៉ាងណាលោកគ្មានបំណងគោរពតាមលក្ខខណ្ឌតម្រូវនេះទេ។[5]

ការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សនិងសកម្មជនសិទ្ធិមនុស្សតាមអំពើចិត្ត ហើយបន្ទាប់មកដោះលែងវិញដោយពឹងផ្អែកលើការចុះហត្ថលេខាលើលិខិតស្នាមយល់ព្រមបញ្ឈប់សកម្មភាពតស៊ូមតិជាដើម បានចាប់ផ្តើមកើតឡើងជាហូរហែនៅក្នុងខែមករា ឆ្នាំ២០១៤ នៅពេលដែលរដ្ឋាភិបាលចាប់ផ្តើមបង្ក្រាបទៅលើការតវ៉ានានា។ ចាប់តាំងពីពេលនោះមក ការឃុំខ្លួនអ្នកតវ៉ានិងសកម្មជនព្រមទាំងការតម្រូវឱ្យពួកគេចុះហត្ថលេខាលើលិខិតស្នាមនានាហាក់ក្លាយទៅជាការអនុវត្តជាស្តង់ដារទៅហើយ។ ករណីនេះត្រូវបានអនុវត្តទៅលើបុគ្គលយ៉ាងហោចចំនួន ១៧ រូប នៅរយៈពេលបីដងក្នុងខែមករា នៅឆ្នាំកន្លងទៅនោះ នេះបើយោងតាមការលើកឡើងក្នុងកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្ស រំលោភលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំ" ដែលបានចេញផ្សាយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ នាពេលនោះ ម.ស.ម.ក បានលើកឡើងថាការអនុវត្តនេះត្រូវបានធ្វើឡើងដោយឡែកពីគ្នាកាលពីឆ្នាំមុនៗ ដូចជាក្នុងខែមេសា ឆ្នាំ២០១១ ខែ

[3] បែន សុឃាន "សកម្មជនសហជីពចំនួនប្រាំមួយនាក់ត្រូវបាននគរបាលចាប់ខ្លួន ក្រោយមកត្រូវបានដោះលែងវិញនៅក្រុងបាវិត" កាសែត *ដឹខេមបូឌា ដេលី* ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈ៖ http://bit.ly/1PYBGtI។

[4] សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក "សកម្មជនអង្គការមាតាធម្មជាតិ ត្រូវបានចាប់ខ្លួនក្នុងទីក្រុងភ្នំពេញ ខណៈ ដែលប៉ុនប៉ងធ្វើការតវ៉ាប្រឆាំងនឹងសកម្មភាពបូមខ្សាច់ក្នុងខេត្តកោះកុង" ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ អាចស្វែងរកបាន http://bit.ly/1ZsODlk។

[5] អូន ភាព " នគរបាល ចាប់ខ្លួនសកម្មជន បន្ទាប់មកដោះលែងវិញនៅខេត្តកោះកុង " កាសែត *ដឹ ខេមបូឌាដេលី* ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈ ៖ http://bit.ly/1K7HHxG។

កក្កដា និងខែវិច្ឆិកា ឆ្នាំ២០១៣។[6] ដូច្នេះហើយ ទោះបីជាយុទ្ធសាស្ត្រនេះត្រូវបានប្រើប្រាស់យ៉ាងតិចតាំងពីឆ្នាំ ២០១១ ក៏ដោយ ក៏យុទ្ធសាស្ត្រនេះត្រូវបានអនុវត្តកាន់តែរាលដាលចាប់ពីខែមករា ឆ្នាំ២០១៤។

## អនិត្យានុកូលភាពនៃការអនុវត្ត

យុទ្ធសាស្ត្រទាំងនេះបង្ហាញនូវអនិត្យានុកូលភាពយ៉ាងច្បាស់។ ការចាប់ខ្លួនអ្នកតវ៉ាដើម្បីបំបែកនូវការតវ៉ា និងការរារាំងមតិជំទាស់គឺជាការរំលោភទៅលើសិទ្ធិសេរីភាពខាងការជួបប្រជុំ និងការបញ្ចេញមតិដូចមានចែងក្នុង មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ។ ទោះបីជាការរឹតត្បិតលើសិទ្ធិទាំងនេះដើម្បីហេតុផលសុវត្ថិភាពសាធារណៈត្រូវបាន អនុញ្ញាត ក៏ដោយ តែការរឹតត្បិតនោះត្រូវតែស្របទៅតាមគោលបំណងនៃច្បាប់ ហើយត្រូវធ្វើឡើងដោយសមា មាត្រទៅនឹងការគំរាមកំហែងដែលបានកើតឡើង។ ក្នុងករណីទាំងអស់ខាងលើនេះ អ្នកតវ៉ាមិនបានបង្ហាញនូវការ គំរាមកំហែងជាក់ស្តែងណាមួយឡើយ ព្រោះអ្នកទាំងអស់នោះបានចូលរួមក្នុងការតវ៉ាដោយអហិង្សា។ ចំពោះលិខិត ស្នាមដែលបានចុះហត្ថលេខា ការរឹតត្បិតជាក់ស្តែងទៅលើបុគ្គលដោយគ្មានកំណត់ហេតុនៃការតវ៉ាហិង្សាមិនអាចផ្ត ល់យុត្តិកម្មថាជាលិខិតស្នាមដែលសមាមាត្រ ឬត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ។ មន្ត្រីរដ្ឋាភិបាលបានទទួលស្គាល់ថា គ្មានហេតុផលផ្លូវច្បាប់ណាមួយក្នុងការចាប់ខ្លួនទាំងនេះទេ តែជា"*ការអប់រំ*" ដល់អ្នកតវ៉ាទាំងនោះដើម្បីរារាំងពួកគេ ក្នុងការធ្វើសកម្មភាពទៀត។ ផ្ទុយទៅវិញ លោក ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនាពេល ថ្មីៗនេះត្រូវបានដកស្រង់សម្តីថា បានស្នើឱ្យអង្គការនានា "ឈប់បង្រៀនប្រជាពលរដ្ឋធ្វើការតវ៉ា"។ ដូច្នេះហើយផ្នត់ គំនិតប្រឆាំងនឹងសិទ្ធិតវ៉ាបានរាលដាលនៅក្នុងចំណោមអាជ្ញាធរកម្ពុជា។ ដោយសារមានការលើកឡើងនូវពាក្យសម្តី ដូច្នេះពីមន្ត្រីជាន់ខ្ពស់ វាពុំមែនជារឿងគួរឱ្យភ្ញាក់ផ្អើលឡើយ ដែលថាកង្វះខាតការគោរពសិទ្ធិរបស់បុគ្គលបានកើត មានក្នុងចំណោមមន្ត្រីនគរបាលថ្នាក់ទាប និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត។

ម្យ៉ាងទៀត លិខិតដែលចុះហត្ថលេខាហើយនោះមិនអាចមានអនុភាពតាមផ្លូវច្បាប់ឡើយ។ ជាញឹកញាប់ នគរបាលបានធ្វើការបដិសេធដោះលែងអ្នកជាប់ឃុំ រហូតទាល់តែពួកគេព្រមចុះហត្ថលេខាលើលិខិតស្នាមទាំងនេះ ឬបានគំរាមចាត់វិធានការទៅលើពួកគេ ប្រសិនបើពួកគេមិនព្រមចុះហត្ថលេខាទេនោះ។ ដូច្នេះពួកគេបានចុះហត្ថ លេខាលើលិខិតក្រោមការគំរាមកំហែង ដែលនេះមិនអាចឆ្លុះបញ្ចាំងពីកិច្ចសន្យាបានធ្វើឡើងដោយសុទ្ធចិត្តរបស់ បុគ្គលនោះទេ។ ជាទូទៅលក្ខខណ្ឌមានចែងក្នុងលិខិតនោះរំលោភទៅលើសិទ្ធិសេរីភាពដើរហើររបស់បុគ្គល និងសិទ្ធិ សេរីភាពរួចផុតពីការចាប់ខ្លួនតាមអំពើចិត្ត។ យោងតាមស្ថានភាពខាងលើ លិខិតនេះថែមទាំងបង្ខំឱ្យបុគ្គលជាប់ឃុំ ធ្វើសកម្មភាពប្រឆាំងទៅលើអ្នកតវ៉ាដូចខ្លួន ដែលនេះគឺជាការរំលោភទៅលើសិទ្ធិរបស់ភាគីទាំងពីរ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការចាប់ខ្លួនចុងក្រោយបង្អស់ដោយពុំមានការចោទប្រកាន់ព្រោះតែគោលបំណងនយោបាយនេះ គឺជា ឧទាហរណ៍មួយផ្សេងទៀតរបស់រដ្ឋាភិបាលក្នុងការប្រើប្រាស់យុទ្ធសាស្ត្រគំរាមកំហែងប្រឆាំងទៅលើអ្នកតវ៉ា។ ការ ទទួលស្គាល់របស់អភិបាលរងជុំវិញហេតុផលនយោបាយនៅពីក្រោយការចាប់ខ្លួននេះ បង្ហាញពីការមិនគោរពចំពោះ

[6] សម្រាប់ព័ត៌មានបន្ថែម សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្ស រំលោភ លើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំ" បានចេញផ្សាយនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ អាចស្វែងរកបានតាមរ យៈ ៖ http://bit.ly/1N6PhZj។

នីតិរដ្ឋ ដោយគ្មានធន្ទះផ្តល់យុត្តិកម្មច្បាស់លាស់ចំពោះការចាប់ខ្លួននេះទេ។ ការអនុវត្តនេះបង្ហាញឱ្យឃើញពីការមិនគោរពរបស់មន្ត្រី និងមន្ត្រីអនុវត្តច្បាប់ជាច្រើនលើសិទ្ធិរបស់ប្រជាពលរដ្ឋដូចមានចែងក្នុងរដ្ឋធម្មនុញ្ញពោលគឺសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ ម្យ៉ាងទៀត ការតម្រូវឱ្យជនជាប់ឃុំចុះហត្ថលេខាលើលិខិតនៅមុនពេលដោះលែងពួកគេ ជាយុទ្ធសាស្ត្រមួយដែលត្រូវបានប្រើយ៉ាងពេញនិយមនាពេលបច្ចុប្បន្ន ដែលប៉ះពាល់ដល់សិទ្ធិមនុស្ស និងផ្ទុយទៅនឹងច្បាប់កម្ពុជា។

ដោយសារមានការបំពារបំពានសិទ្ធិមនុស្សទាំងនេះ ម.ស.ម.ក សូមជូនអនុសាសន៍ដូចខាងក្រោម ៖

- ម.ស.ម.ក សូមស្នើជាថ្មីម្តងទៀតនូវសំណើដែលបានធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ស្នើរដ្ឋាភិបាលបញ្ឈប់ការបង្ខិតបង្ខំអ្នកតវ៉ាឱ្យចុះហត្ថលេខាដោយមានលក្ខខណ្ឌដើម្បីរួចផុតពីការឃុំខ្លួន។
- ម.ស.ម.ក សូមស្នើជាថ្មីម្តងទៀតឱ្យធ្វើមោឃភាពលើលិខិតដែលបានចុះហត្ថលេខាទាំងអស់។
- ម.ស.ម.ក សូមស្នើជាថ្មីម្តងទៀតឱ្យបញ្ឈប់ការប្រើប្រាស់នគរបាល និងប្រព័ន្ធយុត្តិធម៌ដើម្បីហេតុផលនយោបាយ និងស្នើឱ្យគោរពដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលជំទាស់នឹងរដ្ឋាភិបាល។
- ម.ស.ម.ក សូមជូនអនុសាសន៍ដល់រដ្ឋាភិបាលធ្វើកំណែទម្រង់ទៅលើដំណើរការនៃការចាត់ចែងសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា គោរពសិទ្ធិជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ដោះស្រាយនូវទំនាស់ដីធ្លី និងបង្កើតប្រព័ន្ធដោះស្រាយទំនាស់ឱ្យកាន់តែយុត្តិធម៌សម្រាប់បុគ្គលនានា។ ទំនាស់ដីធ្លីគឺជាបុព្វហេតុនាំឱ្យមានការតវ៉ានានាជាច្រើនដែលបានបង្ក្រាបពីសំណាក់រដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ប្រសិនបើទំនាស់ទាំងនេះត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព នោះនឹងមានការលើកទឹកចិត្តតិចតួចដល់នគរបាលក្នុងការប្រើមធ្យោបាយខុសច្បាប់។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ + ៨៥៥ (០) ១៧ ៥២៨ ០២១ ឬ អ៊ីម៉ែល ៖ chhunly.chhay@cchrcambodia.org ឬ លោក ផាត ដឺប្រូន ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ៨៩ ៥៣៦ ២១៥ ឬ អ៊ីម៉ែល៖ pat.debrun@cchrcambodia.org។**